**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្ដីជូនព័ត៌មាន
## ស្ដីពី
## កម្មវិធីចាក់វ៉ាក់សាំងកូវីដ-១៩ ជាបន្ត ចាប់ពីថ្ងៃទី០៥ ខែមិនា ឆ្នាំ២០២១

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងសន្និសីទសារព័ត៌មានប្រកាសយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ដោយឈរលើ **<u>គោលការណ៍ស្ម័គ្រចិត្ត និង ឥតគិតថ្លៃ</u>**៖

១. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (Astra Zeneca/Serum Institute of India "COVISHIELD™") នឹងត្រូវផ្ដល់ជូនជាពិសេសដល់ក្រុមមនុស្សដែលងាយរងគ្រោះនឹងជំងឺកូវីដ-១៩ មានអាយុចាប់ពី **<u>៦០ឆ្នាំឡើង</u>** ទៅទាំងអស់ដែលរស់នៅក្នុង **រាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ** សូមអញ្ជើញទៅទទួលវ៉ាក់សាំងនេះ ដោយកន្លែងចាក់វ៉ាក់សាំងមាននៅ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ទីរពេទ្យព្រះអង្គឌួង មន្ទីរពេទ្យ កុមារជាតិ និងនៅតាមមន្ទីរពេទ្យបង្អែករាជធានី/ខេត្ត ព្រមទាំងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ដែលនៅជិតគេហដ្ឋានលោកអ្នក ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ ការចាក់វ៉ាក់សាំងនេះ គឺនឹងផ្ដល់ជូនដល់ក្រុមអាយុចាប់ពី **<u>៦០ឆ្នាំ</u>** ឡើងទៅ ទាំងជនជាតិខ្មែរ រួមទាំងជនចូលនិវត្តន៍។ ចំណែក ឥស្សរជនជាន់ខ្ពស់ ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ត្រូវអញ្ជើញទៅទទួលវ៉ាក់សាំងនៅមន្ទីរពេទ្យកាល់ម៉ែត។

២. ចំពោះបុគ្គលិកសុខាភិបាល កងកម្លាំងប៉ូលីសចំណុះស្នងការរាជធានី/ខេត្ត មន្ត្រីរាជការស៊ីវិលជួរមុខ និងមន្ត្រីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អាជ្ញាធរខេត្ត ស្រុក ឃុំ/សង្កាត់ ភូមិ កម្មករប្រមូលសម្រាម ដែលមានអាយុចាប់ពី **<u>១៨ ដល់ ៥៩ឆ្នាំ</u>** សូមបន្តមកទទួលវ៉ាក់សាំង (ស៊ីណូហ្វាម "Sinopharm Beijing Institute of Biological Products") ដែលជាជំនួយមនុស្សធម៌ដ៏ថ្លៃថ្លា របស់សាធារណរដ្ឋប្រជាមានិតចិន នៅតាមមន្ទីរពេទ្យបង្អែករាជធានី/ខេត្ត និង ស្រុកប្រតិបត្តិ ដែលនៅជិតលោកអ្នក (ទៅតាមទីកន្លែងដែលក្រសួងធ្លាប់បានជូនសេចក្ដីព័ត៌មានរួចហើយដែរនូវឈ្មោះទីតាំងដែលមានចាក់វ៉ាក់សាំងនេះ)។ ការចាក់វ៉ាក់សាំងនេះ គឺនឹងផ្ដល់ជូនដល់ក្រុមអាយុចាប់ពី ១៨ឆ្នាំដល់ ៥៩ឆ្នាំ ទាំងជនជាតិខ្មែរដែលស្ថិតនៅក្នុងក្រុមមនុស្សដែលក្រសួងធ្លាប់បានចេញសេចក្ដីជូនព័ត៌មានមុនៗរួចហើយ។ ដោយឡែក សិស្សនិស្សិតដែល ត្រូវត្រឡប់ទៅបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ឬប្រទេសផ្សេងៗ សូមទៅចាក់វ៉ាក់សាំង តាមក្រុមអាយុនេះ នៅតាមទីកន្លែងដូចបានជម្រាបជូនខាងលើនេះ។

៣. សម្រាប់ជនបរទេសទាំងអស់ដែលមានអាយុពី ១៨ឆ្នាំឡើងទៅ និងដែលកំពុងបំពេញបេសកម្ម ឬកំពុង ធ្វើធុរៈកិច្ច និងកំពុងស្នាក់នៅក្នុងប្រទេសកម្ពុជា ដូចជាមន្ត្រីការទូត មន្ត្រីអង្គការសហប្រជាជាតិ អង្គការ អន្ត



ទីស្ដីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធុរជនជាដើម ដែលមានអាសយដ្ឋានរស់នៅក្នុងកម្ពុជាពិតប្រាកដ សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត ដែលអាចជ្រើសរើសទីកន្លែង និងវ៉ាក់សាំងទាំងពីរប្រភេទខាងលើ ដើម្បីចាក់បានដែរ។

**សម្គាល់៖**

បន្ថែមលើនេះ ដោយក្រសួង បានពង្រីកទីតាំងចាក់វ៉ាក់សាំងដល់គ្រប់រាជធានី-ខេត្តទាំង២៥ និងដើម្បីជម្រុញការចាក់វ៉ាក់សាំងឱ្យមានវិសាលភាពកាន់តែទូលំទូលាយ នៅទីតាំងចាក់វ៉ាក់សាំងដែលមានការអនុញ្ញាតពីក្រសួងរួចហើយនោះ ត្រូវបន្តការងារចាក់វ៉ាក់សាំងជូនប្រជាជនតាមក្រុមមនុស្ស នៅរៀងរាល់ថ្ងៃ (ទាំងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកផ្លូវការ) ចាប់ពីម៉ោង ០៨:០០ នាទីព្រឹក ដល់ ម៉ោង ១៧:០០ នាទីល្ងាច (ដោយសម្រាកពិសារអាហារថ្ងៃត្រង់ពីម៉ោង ១២:០០នាទី ដល់ម៉ោង ១៤:០០នាទី)។

សម្រាប់ក្រុមមនុស្ស ដែលក្រសួង ធ្លាប់បានចេញសេចក្តីជូនព័ត៌មានជាហូរហែរចាប់តាំងពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ រួចមកហើយនោះ ហើយដែលមិនទាន់បានមកចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្ត សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំង នៅតាមទីតាំងនានាដែលក្រសួងធ្លាប់បានជូនព័ត៌មានរួចហើយ (មានដាក់ផ្សាយក្នុងទំព័រហ្វេស បុករបស់ក្រសួងសុខាភិបាល)។

សម្រាប់វ៉ាក់សាំង **ស៊ីណូហ្វាម** (SINOPHARM) ក្រសួង ក៏សូមក្រើនរំលឹកដល់អ្នកដែលបានចាក់វ៉ាក់សាំងលើកទី១ (ដូសទី១) រួចហើយ សូមអញ្ជើញមកទទួលការចាក់វ៉ាក់សាំងជាលើកទី២ (ដូសទី២) ក្នុងរយៈពេល **ពី ១៤ ទៅ ២៨ថ្ងៃ** បន្ទាប់ពីថ្ងៃចាក់លើកទីមួយ។ (មិនឱ្យលើសពី២៨ថ្ងៃ) នៅទីតាំងដែលបុគ្គលបានចាក់លើកទី១ កុំបីអាក់ខានឡើយ។

សម្រាប់វ៉ាក់សាំងអាស្ត្រាហ្សាណីកា ផលិតនៅឥណ្ឌា ឬ**កូវីសែល** (COVISHELD™) លោកអ្នកដែលបានចាក់លើកទី១ (ដូសទី១) រួចហើយ សូមអញ្ជើញទៅចាក់លើកទីពីរ (ដូសទី២) នៅកន្លែងដែលបានចាក់លើកទី១ **ចន្លោះពី ៤ ទៅ ៨សប្តាហ៍** បន្ទាប់ពីថ្ងៃដែលបានចាក់លើកទី១។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជន នូវក្រុមមនុស្សផ្សេងៗទៀត ដែលនឹងត្រូវអញ្ជើញទៅទទួលវ៉ាក់សាំងកូវីដ-១៩ ដោយស្ម័គ្រចិត្តនាពេលក្រោយៗទៀត។

សូមបងប្អូនប្រជាពលរដ្ឋដែលនៅក្នុងក្រុមមនុស្សផ្សេងៗទៀត ដែលស្ម័គ្រចិត្តចាក់វ៉ាក់សាំងកូវីដ-១៩ មេត្តាអធ្យាស្រ័យប្រសិនបើមិនទាន់ដល់វេនរបស់ខ្លួនទេនោះ សូមមេត្តារង់ចាំបន្តិចសិន ព្រោះវ៉ាក់សាំងមានកំណត់ចំនួននៅពេលនេះ ហើយក្រសួង សង្ឃឹមថា នឹងអាចមានវ៉ាក់សាំងមកជាបន្តបន្ទាប់ទៀតនៅក្នុងឆ្នាំ២០២១នេះ ដែលមួយផ្នែក គឺជាជំនួយពីសាធារណរដ្ឋប្រជាមានិតចិន និងមួយផ្នែកទៀតជាជំនួយមកពីមជ្ឈមណ្ឌលកូវ៉ាក់ ដែលអាចផ្តល់ជូនបងប្អូនក្នុងក្រុមផ្សេងៗទៀតបាននាពេលខាងមុខនេះ។

ថ្ងៃសុក្រ ៧រោច ខែផល្គុន ឆ្នាំជូត ទោស័ក ពស ២៥៦៤.

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមិនា ឆ្នាំ២០២១ ✓



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩